ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ទីស្ដីការគណៈរដ្ឋមន្ត្រី
*Office of the Council of Ministers*
លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
*Secretariat of the Task Force*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

# សេចក្ដីប្រកាសព័ត៌មាន
# Press Release

## ការតែងតាំងមន្ត្រីរដ្ឋបាលជាន់ខ្ពស់សំរាប់តុលាការជំរះក្ដីមេដឹកនាំខ្មែរក្រហម

## ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល នៃអង្គជំនុំជំរះវិសាមញ្ញត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ

យោងទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មន្ត្រីរដ្ឋបាលជាន់ខ្ពស់សំរាប់តុលាការជំនុំជំរះក្ដីមេដឹកនាំខ្មែរក្រហមត្រូវបានតែងតាំងរួចហើយ ។

ព្រះមហាក្សត្រ**ព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** បានឡាយព្រះរាជក្រឹត្យតែងតាំង ឯកឧត្ដម **ស៊ាន វិសុទ្ធ** ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជំរះវិសាមញ្ញ និងលោកស្រី **មីសែល លី** ជាអនុប្រធានការិយាល័យរដ្ឋបាល ជាតំណែងដែលលោកស្រីត្រូវបានប្រកាសតែងតាំងកាលពីថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០០៥ ដោយលោកអគ្គលេខាធិការ អ.ស.ប ។

ឯកឧត្ដម **ស៊ាន វិសុទ្ធ** ធ្លាប់បានបំពេញនូវតំណែងរដ្ឋបាលសំខាន់ៗមួយចំនួនក្នុងរដ្ឋបាលកម្ពុជា (រួមមានទីស្ដីការ គណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងលេខាធិការដ្ឋានឧត្ដមក្រុមប្រឹក្សាជាតិជាន់ខ្ពស់) ហើយចាប់តាំងពី ឆ្នាំ១៩៩៩ មក បានបំពេញតួនាទីជាលេខាធិការប្រតិបត្តិរបស់ក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា សំរាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសសំរាប់រៀបចំការជំនុំជំរះក្ដីមេដឹកនាំខ្មែរក្រហម ។ ឯកឧត្ដម **ហែម ក្រាញ់ តូនី** អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវបានតែងតាំងជាប្រធានការិយាល័យរដ្ឋបាលបំរុងនៅក្នុងព្រះរាជក្រឹត្យ ជាមួយគ្នានេះ ។

លោកស្រី **មីសែល លី** នឹងដឹកនាំគណៈប្រតិភូ អ.ស.ប មួយ ដើម្បីធ្វើការវាយតំលៃអំពីការចាប់ផ្ដើមដំណើរការ មកកាន់ទីក្រុងភ្នំពេញនៅដើមខែធ្នូខាងមុខនេះ ដើម្បីពិភាក្សាជាមួយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា អំពីចំនុចលំអិតនៃការបង្កើតអង្គជំនុំជំរះវិសាមញ្ញនៅក្នុងពេលប៉ុន្មានខែខាងមុខនេះ ។

ឥឡូវនេះទាំងខាង អ.ស.ប ទាំងខាងកម្ពុជា កំពុងស្ថិតនៅក្នុងដំណើរការជ្រើសរើសមន្ត្រីតុលាការ (ចៅក្រម សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា) កំណត់អំពីតំណែងរដ្ឋបាលសំខាន់ៗដទៃទៀត និងធ្វើការរៀបចំផ្សេងៗ សំរាប់ការបង្កើតអង្គជំនុំជំរះវិសាមញ្ញ ។

នៅពេលណាដែលទទួលបាននូវថវិកាគ្រប់គ្រាន់នោះ ការរៀបចំចាំបាច់ផ្សេងៗនឹងអាចចាប់ផ្ដើមដើម្បីធ្វើអោយអាគារអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទថ្មី នៅកំបូលអាចប្រើការបានជាទីកន្លែងជំរះក្ដី និងបំរើសកម្មភាពរដ្ឋបាល របស់អង្គជំនុំជំរះវិសាមញ្ញ ។

#41, Russian Federation Blvd, Phnom Penh, Cambodia
Phone/Fax: 023 428 952 Email: stf@nida.gov.kh, Website: www.cambodia.gov.kh/krt/

នៅពេលបច្ចុប្បន្ននេះ ថវិកាចំណែក អ.ស.ប ចំនួន **៤៣ លានដុល្លារអាមេរិក** មានស្មើរគ្រប់ចំនួនហើយ ប៉ុន្តែចំណែកកម្ពុជា នៅខ្វះចំនួន **១០.៨ លានដុល្លារអាមេរិក**ទៀត។ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការអំពាវនាវដល់រដ្ឋាភិបាល ប្រទេសផ្សេងៗទៀត សូមជួយផ្តល់វិភាគទានអោយបានឆាប់ដើម្បីបំពេញកង្វះខាតនេះតាមរយៈជំនួយទ្វេភាគី។

ធ្វើនៅភ្នំពេញ.ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥